KhmerPost USA

សុបិន : (267) 253-3947, សែម : (781) 244-0522


# ហុង ណោត ជាសមាជិកសភា ខ្មែរដំបូងបង្អស់នៅលីន



ដោយ : ពិន សំខុន

លីន : លោក ហុង ណោត បានឡើងកាន់ដំណែងជាសមាជិកសភានៅក្រុងលីនរដ្ឋម៉ាសាឈូសែតតាំងពីដើមខែ មករា ឆ្នាំ ២០១២ -លោកជាតំណាងរាស្ត្រដើមកំណើតខ្មែរ និងអាស៊ីលើកទី១ ដែលឡើងកាន់តំណែងដ៏ខ្ពង់ខ្ពស់នៅក្នុងតំបន់ ។

ជួបសម្ភាសន៍នៅគេហដ្ឋាននៅទីក្រុងលីនរបស់លោក កាលពីថ្ងៃទី៨ មេសា នេះ លោកបានឆ្លើយនឹងសំនួរខ្មែរផុសជូនជាព័ត៌មានដូចតទៅ:

**ហុង ណោត : តួនាទីរបស់ខ្ញុំគឺសមាជិកសភាក្រុង** City Councillor at Large

**ខ្មែរផុស :** តើលោកមានភារកិច្ចធ្វើអ្វីខ្លះ?

**ហុង ណោត :** តួនាទីមានច្រើន ដូចជាអនុម័តលើថវិកា ដូចជានៅពេលចៅហ្វាយក្រុងតែងតាំងនរណា **តទៅទំព័រទី ០៦**

**មាតិការឿង** **ទំព័រ**


១-សួន សេរីវដ្ឋា សាងស្នេហាជាមួយ ម៉ម សុដង់ណូ...០៤

២-សមាគមគាំទ្រខ្មែរ&បញ្ជីសប្បុរសជន................០៦

៣-ចោសសំអាតទីតាំងគ្រឿងញៀន........................១២

២-ប្រវត្តរណសិរ្សរំដោះជាតិពលរដ្ឋខ្មែរ....................១៧

១-United Cambodian American................២០


VOL. 06 ISSUE 106 May.04th - .24th, 2012

# តើគណបក្ស សម រង្ស៊ី នៅឡូវែលចង់បានអ្វីខ្លះពីកម្ពុជា?



ដោយ : ពិន សំខុន

លោក សម រង្ស៊ី នៅពេលជួបប្រជុំសមាជិកគណកម្មាធិការ នាយក សាខា រដ្ឋមាសាឈូសែត បានស្នើឱ្យមានយោបល់ ដើម្បីលោកពាំនាំទៅឱ្យគណកម្មាធិការកណ្តាលនៅកម្ពុជា ដើម្បីឱ្យមានការកែទម្រង់ការអនុវត្តន៍នយោបាយរបស់គណបក្ស សម រង្ស៊ី

**លោក កែម ស៊ាយ ប្រធានសាខាបក្ស**

**តទៅទំព័រទី០៨**


Accepting New Clients

សូមស្វាគមន៍ដល់ភ្ញៀវគ្រប់ប្រភេទ

Immigration • Divore • Auto Crash

អន្តោប្រវេសន៏ គ្រោះថ្នាក់រថយន្ត លែងលះប្តីប្រពន្ធ

Law Office of Thomas Stylianos Jr. •287 Appleton St. Lowell MA 01852

ការិយាល័យ មេធាវី ថំរម៉ាស ស្តាលីយ៉ាណូស

Call: Narong, Sophea or Thomas សូមទូរស័ព្ទមក: ណារ៉ុង, សោភា, ឬធំ

978-459-5000 or 800-308-3766

Only Licensed in Massachusets



天 THIÊN TÂN 新 食坊

Vietnamese & Chinese Restauranl

តំម្លៃពិសេសនេះសំរាប់តែថ្ងៃបុណ្យមាតាទេ

$88

ភោជនីយដ្ឋាន ឋានតឹង





MOTHER´S DAY SPECIAL $88 ម្ហូបពិសេសសំរាប់ថ្ងៃបុណ្យមាតា

Fish Maw Soup..........ស៊ុបក្រពះត្រី

Fresh Steaming Fish..........ត្រីស្រស់ចំហុយ

Lobster with Scalloin and Ginger..........ឆាឡបស្ទ័រជាមួយខ្ទឹមក្រហមនិងខ្ញី

Clam sauté with black bean sauce..........ឆាគ្រំ និងទឹកសណ្តែកសៀង

Snow pea tips with garlic..........ត្រួយសណ្តែកស្ទូភីឆាជាមួយខ្ទឹមស

Dessert..........បង្អែម

Family of 4-6..........សម្រាប់គ្រួសារ៤-៦នាក់

Please call for Reservation..........សូមអញ្ជើញទូរស័ព្ទដើម្បីរក្សាតុ

215-904-6543/267-216-4834

LUNCH SPECIAL $5

អាហារថ្ងៃត្រង់ពិសេស 11-3PM

ហ៊ើ-ធាយស្រួប តម្លៃ $5

មានញាំស្វាយ

BYOB Welcome យកស្រាពចូលពិសារបាន

Birthday/ Function Party available (15 Tables)





VMART

ហាងលក់ម្ហូបអាហារអន្តរជាតិ

ធំជាងគេនៅអាស៊ីក្នុងតំបន់ New England

176 Narragansett Ave

Providence, RI 02907

(401) 490-0612

vmartprovidence.com





-From I95 north heading south, take exit 17 (Roger Williams Zoo)

-From I95 south heading north, take exit 16

បើក៧ថ្ងៃក្នុងមួយសប្តាហ៍

មកមើលម្ហូបអាហាររៀងរាល់សប្តាហ៍


A Taste of CAMBODIA
NOW FREE Delivery
FLAVORFUL AUTHENTIC CAMBODIAN RESTAURANT - A FAST CASUAL ALTERNATIVE.
ឈ្ងុយ
ឆ្ងាញ់
ឆាប់រហ័ស
ប្រហុកខ្ទិះ
ត្រីចៀនជូន
អាម៉ុកត្រី
Kavei
ម្ហូបខ្មែរទាន់ចិត្ត
សម្លកកូរ ម្ជូរគ្រឿង ម្ជូរគ្រៃ
ញាំស្ដៅ ភ្លាសាច់គោ ឆាគ្រឿង កប់ផ្សិត
2223-25 S 7TH ST. PHILADELPHIA PA 19148
OPEN 6 DAYS A WEEK 10AM-8PM / TUESDAY - CLOSED
tel: 215.755.2151 fax: 215.755.2115
KAVEI Xpress
www.kaveirestaurant.com
EAT IN
TAKE OUT
*FREE DELIVERY
CATERING SERVICES
*Free delivery for limited area only . Beyond area $3 fee . Min. order $15

# SHEN YUN 神韻晚會 2012

**MAY 8-9**
**MERRIAM THEATER**

*The Perfect Gift for Mother's Day!*
**www.ShenYun2012.com**



**REVIVING 5,000 YEARS OF CIVILIZATION**
2012 TOUR RETURNS WITH LIVE ORCHESTRA

## SHEN YUN PERFORMING ARTS

*— Experience the world's premier classical Chinese dance company.*

**SHEN YUN.** For Chinese, the words evoke a sense of wonder, magic, and the divine. To audiences who have seen it, they recall the experience of a lifetime—a moment so powerfully beautiful it touches the soul.

Discover the glory of a fantastically rich culture, that of classical China, brought to life through brilliantly choreographed dance and mesmerizing, all-original orchestral compositions. Magnificently costumed dancers—the world's elite—move in poetic arrangements that evoke pastoral beauty, imperial drama, and the glory of an ancient civilization. This season, discover what art was meant to be. Discover Shen Yun.

**REVIVING 5,000 YEARS OF CIVILIZATION.**

For 5,000 years in China, culture was heralded as a divine gift. Its glory was long the inspiration of countless artists and poets, until this heritage was nearly lost...

Based in New York, Shen Yun Performing Arts seeks to revive this once-majestic tradition by creating a production worthy in its beauty of this noble history—something that enriches the lives of audiences in powerful, lasting ways.

## "THE BEST! THE BEST! THE BEST!"

*— **Charles Wadsworth,** founding artistic director of the Chamber Music Society of Lincoln Center*

**"Shen Yun is absolutely No.1, the top one in the world, absolutely the best..."**
*— **Ken Wells,** legendary principal dancer of the English National Ballet*

"I probably have reviewed over 3,000 to 4,000 shows since 1942. I will give this production 5 stars. **That's the top... I've never seen anything like this.** I mean I've seen enough Broadway shows that still cannot compare to what I saw tonight. **The best word to use was 'mind-blowing.'"**
*— **Richard Connema,** theatre critic for Talkin' Broadway*

**"Demonstrating the highest realm in arts. Shen Yun inspires the performing arts circle."**
*— **Chi Cao,** principal dancer of Birmingham Royal Ballet*

**"My heart was open and I started to cry. I'm blown away, I'm awestruck... The spirit of hope, beauty, blessing is a fabulous gift to us."**
*— **Sine Mckenna,** award-winning Celtic singer*

**"Elegant and very athletic, very skilled."**
*— **John McColgan,** Riverdance Producer*



- **STUNNING CLASSICAL CHINESE DANCE...**
  *One of the most expressive art forms in the world...*
- **ALL-ORIGINAL MUSIC PERFORMED BY AN ORCHESTRA ...**
  *Combining Western and Chinese instruments...*
- **EXQUISITE, HANDCRAFTED COSTUMES...**
  *All matched to animated, digital backdrops.*
- **THE SHOW THAT'S LEAVING MILLIONS IN AWE.**

*Don't Miss This Extraordinary Gift From the Divine Land.*

**ORDER YOUR TICKETS TODAY**

DATE & TIME
May 8, 2012 Tue. 7:30pm
May 9, 2012 Wed. 7:30pm

VENUE
Merriam Theater
250 South Broad Street
Philadelphia, PA 19102

TICKET PRICES (PLUS FEES)
Orchestra $100 $120 $140 $150
Balcony $60 $80 $120

ORDER BY PHONE
Phone: 215-893-1999 (box office)
215-475-4492 (hotline)

TWO SHOWS ONLY

ORDER ONLINE
www.kimmelcenter.org
**www.ShenYun2012.com**

*The Perfect Gift for Mother's Day!*

PRESENTED BY
Greater Philadelphia Falun Dafa Association

# សួន សេរីរដ្ឋា សាងស្នេហាជាមួយ ម៉ម សុណង់ដួ

**អ៊ឹម លឿម**

ក្នុងចំណោមមជ្ឈដ្ឋានអ្នកតាមដានព្រឹត្តិការណ៍នយោបាយកម្ពុជា គេប្រាកដជាស្គាល់យ៉ាងច្បាស់អំពីឈ្មោះរបស់អ្នកនយោបាយសំខាន់ៗដែលកំពុងនៅក្នុងស្រុក និងកំពុងនៅក្រៅស្រុក ដូចជាលោក ហ៊ុន សែន លោក សម រង្ស៊ី លោក កឹម សុខា ជាដើម ។ តែសម្រាប់អ្នកនយោបាយខ្ចីវស្សាឈ្មោះ សួន សេរីរដ្ឋា ហាក់នៅពុំទាន់បានជ្រួតជ្រាបដល់ស្រទាប់មហាជនតាមដានព្រឹត្តការណ៍នយោបាយកម្ពុជាប៉ុន្មានឡើយ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តីបច្ចុប្បន្នអ្នកនយោបាយក្មេងវ័យ សំដីខ្លាំងឈ្មោះ សួន សេរីរដ្ឋា ត្រូវបានគេចាប់ផ្តើមស្គាល់ និងចាប់អារម្មណ៍ជាបណ្តើរៗតាមរយៈការត្រាច់ចរពីរដ្ឋមួយទៅរដ្ឋមួយក្នុងសហរដ្ឋអាមេរិក និងតាមបណ្តាប្រទេសក្នុងទ្វីបអឺរ៉ុបមួយចំនួន ដើម្បីផ្សព្វផ្សាយអំពីគោលការណ៍នយោបាយរបស់លោក និងបានស្គាល់តាមរយៈវិទ្យុផ្សាយសម្លេង KPPM ជាវិទ្យុផ្សាយសម្លេងសារនយោបាយតាមប្រព័ន្ធអន្តរបណ្តាញ(Internet) ដែលជានិច្ចជាកាលវិទ្យុនេះតែងតែលើកយកនូវសេចក្តីថ្លែងការណ៍សន្ទរកថា និងបទអត្ថាធិប្បាយផ្សេងៗជុំវិញបញ្ហាជនអន្តោប្រវេសន៍យួនខុសច្បាប់អំពើពុករលួយ



កំពុងស៊ីរូងផ្ទៃក្នុងនៅសង្គមកម្ពុជា នាពេលបច្ចុប្បន្ន បញ្ហាប្រព័ន្ធយុត្តិធម៌គ្មានតម្លាភាព ។ល។

"ចលនាអំណាចពលរដ្ឋខ្មែរ" ជាចលនានយោបាយតែពុំមែនគណបក្សនយោបាយមួយដែលមានទិសដៅចម្បងរបស់ខ្លួនក្នុងការផ្តួលរំលំរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នដែលមានលោក ហ៊ុន សែន កំពុងដឹកនាំប្រទេស ។ ចលនានេះក៏ពុំបានពេញចិត្តពេញថ្លើម ឬគាំទ្រនយោបាយរបស់គណបក្សប្រឆាំងទាំងពីរដែលមានលោក សម រង្ស៊ី និងលោក កឹម សុខា ឡើយ ហើយចលនានេះដឹកនាំដោយលោក សួន សេរីរដ្ឋា តែម្តង ។

ថ្លែងទៅកាន់អ្នកគាំទ្រ និងអ្នកចូលស្តាប់ប្រមាណជា១០០នាក់ នៅឯទីក្រុង HUMMEL Stown នៃរដ្ឋផែនស៊ីវេនៀ កាលពីថ្ងៃសៅរ៍ ទី២១ ខែមេសា កន្លងមកនេះ លោក សួន សេរីរដ្ឋា បានថ្លែងថា: "ចលនាពលរដ្ឋខ្មែរជាចលនាដែលមិនប្រើកម្លាំងទ័ព ឬអាវុធយុទ្ធភ័ណ្ឌ ដើម្បីធ្វើរដ្ឋប្រហារណាមួយទៅទម្លាក់រដ្ឋាភិបាលលោក ហ៊ុន សែន ឡើយ ប៉ុន្តែយុទ្ធសាស្ត្ររបស់ចលនាអំណាចពលរដ្ឋខ្មែរ គឺប្រើប្រាស់ និងពឹងផ្អែកលើច្បាប់សំខាន់ៗចំនួនពីរ គឺច្បាប់ធម្មជាតិ និងច្បាប់អន្តរជាតិ ។ ចំពោះច្បាប់ធម្មជាតិ





ត្រូវបានលោក សេរីរដ្ឋា ពន្យល់ថា គឺការគៀងគរដល់ពលរដ្ឋខ្មែរគ្រប់ច្រកល្ហកឱ្យក្រោកឈរប្រឆាំងនឹងរបបផ្តាច់ការនយោបាយបច្ចុប្បន្ន ។ រីឯច្បាប់អន្តរជាតិ គឺប្តឹងទៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ។ លោក រដ្ឋា បន្តថា នៅខែមិថុនា ឆ្នាំ២០១២ ខាងមុខនេះ មហាអំណាចពលរដ្ឋខ្មែរនឹងដាក់ពាក្យបណ្តឹងទៅកាន់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ បន្ទាប់ពីបានស្នាមផ្តិតមេដៃគាំទ្របានចំនួន១លាននាក់ហើយនោះ ។ ថ្វីត្បិតតែចលនាអំណាចពលរដ្ឋខ្មែរមានទិសដៅផ្តួលរំលំរដ្ឋាភិបាលលោក ហ៊ុន សែន មិនខុសពីគណបក្សប្រឆាំងធំៗចំនួនពីរ គឺគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ពិតមែនតែប្រធានចលនាអំណាចពលរដ្ឋខ្មែរដែលមានវ័យ៣៧ឆ្នាំរូបនេះ ហាក់មិនសំចៃមាត់ឡើយ ក្នុងការវាយប្រហារទៅលើគណបក្សប្រឆាំងទាំងពីរ ។ លោកនិយាយថា "គណបក្សប្រឆាំងទាំងពីរគ្រាន់តែចូលរួមបោះឆ្នោតបង្គ្រប់កិច្ច ដើម្បីជួយឱ្យពួកកុម្មុយនិស្តបន្តអំណាចរបស់ខ្លួនតែប៉ុណ្ណោះ ។

ដោយឡែកបើនិយាយពីឈ្មោះ ម៉ម សុណង់ដួវិញ ហាក់មានគេស្គាល់គ្រាន់បើដែរ នៅក្នុងពិភពនយោបាយកម្ពុជា ព្រោះដោយសារតែគាត់ជាប្រធានវិទ្យុសំបុកឃ្មុំធ្លាប់ជាប្រធានគណបក្សសំបុកឃ្មុំ និងជាប្រធានសមាគមអ្នកប្រជាធិបតេយ្យខ្មែរ ហើយជាពិសេសនោះលោកក៏ធ្លាប់បានចូលទ្រុងសារិកាកែវជាមួយលោក កឹម សុខា លោក រ៉ុង ឈុន បានមួយរយៈខ្លីនាគ្រាកន្លងមក ។ ដោយហេតុនេះហើយទើបកិត្តិនាមលើឆាកនយោបាយកម្ពុជាក៏ត្រូវបានគេស្គាល់ជាបណ្តើរៗ ។

ស្ថិតក្នុងវិនាទីនេះ លោក ម៉ម សុណង់ដួ បានក្លាយជាកល្យាណមិត្តចាក់ទឹកមិនលេចជាមួយលោក សួន សេរីរដ្ឋា ។ គូរស្នេហ៍វ័យឆ្ងាយពីគ្នា (សួន សេរីរដ្ឋា អាយុ៣៧ឆ្នាំ លោក ម៉ម សុណង់ដួ អាយុ៧២ឆ្នាំ) នេះ បានញ៉ាំងឱ្យអ្នកគាំទ្រមួយចំនួនបានសម្តែងនូវការពេញចិត្តពេញថ្លើមយ៉ាងខ្លាំង ។ ទោះបីជាលោក ម៉ម សុណង់ដួ មិនបាននិយាយឱ្យចំឈ្មោះគណបក្សប្រឆាំងណាមួយក្តីតែគេឱ្យយល់បានថា លោក ម៉ម សុណង់ដួ ហាក់កំពុងតែវាយសំពោងលើលោក សម រង្ស៊ី និងលោក កឹម សុខា យ៉ាងចាស់ដៃ ។ លោកនិយាយថា "សព្វថ្ងៃអន់ណាស់មិនមែនប្រឆាំងជាមួយរាជរដ្ឋាភិបាលឡើយផ្ទុយទៅវិញ គឺប្រឆាំងតែខ្លួនឯង..."។ ចំពោះប្រយោគមួយធ្វើឱ្យអ្នកគាំទ្រពេញចិត្តតាមរយៈការទះដៃយ៉ាងកងរំពងនោះត្រូវបានកើតឡើង បន្ទាប់ពីលោកថ្លែងថា "អ្នកណាថា គ្មានយួននៅស្រុកខ្មែរ គឺអ្នកនោះជាមនុស្សខ្វាក់..." ។ លោក សុណង់ដួ ដង្កត់ធ្ងន់ថា បច្ចុប្បន្នជនជាតិយួនត្រូវបានរាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់ខ្លាំងជាងជនជាតិកម្ពុជាដែលជាម្ចាស់ស្រុក..."។

ទោះជាយ៉ាងនេះក្តីអ្នកតាមដានព្រឹត្តិការណ៍នយោបាយកម្ពុជា និងអ្នកសារព័ត៌មានកំពុងតែអង្កេតយ៉ាងយកចិត្តទុកដាក់ថា "តើចំណង់ស្នេហ៍របស់បុរសវ័យចំណាស់ ម៉ម សុណង់ដួ ជាមួយអ្នកនយោបាយក្មេងវ័យសំដីផុយប្រផុយគ្រោះថ្នាក់ សួន សេរីរដ្ឋា តើអាចឈានដល់ដំណាក់កាលយូរ ឬឆាប់ប៉ុណ្ណា?"។ ចំលើយដ៏ត្រឹមត្រូវមួយគឺ " រងចាំមើល " ទាំងអស់គ្នា ។ ប៉ុន្តែគេនៅចាំបានថា លោក ម៉ម សុណង់ដួ ក៏ធ្លាប់បានប្រកាសចូលរួមជាមួយគណបក្សសិទ្ធិមនុស្សរបស់លោក កឹម សុខា រួចម្តងមកហើយដែរ ប៉ុន្តែរហូតដល់ដំណាក់កាលនេះជំហរនយោបាយរបស់លោក ម៉ម សុណង់ដួ ហាក់ពិបាកក្នុងការឱ្យតំលៃពីសំណាក់អ្នកតាមដានព្រឹត្តិការណ៍នយោបាយកម្ពុជាណាស់ ។

គួរឱ្យដឹងថា បើយោងតាមសំដីរបស់លោក សួន សេរីរដ្ឋា បានបញ្ជាក់ថា ចលនាអំណាចពលរដ្ឋខ្មែរ និងសមាគមអ្នកប្រជាធិបតេយ្យរបស់លោក ម៉ម សុណង់ដួ គឺជាអង្គការពីរដែលខុសគ្នា ប៉ុន្តែពួកគេរួមគ្នាចាប់ដៃគ្នាធ្វើការជាមួយគ្នា ។ ដូច្នេះពាក្យថា " ចាប់ដៃធ្វើការជាមួយគ្នា " ក៏មិនខុសប៉ុន្មានទៅនឹងពាក្យ "ចងសម្ព័ន្ធភាព" ជាមួយគ្នាឡើយ ។ ទាក់ទងនឹងពាក្យសម្ព័ន្ធភាពនេះលោក សួន សេរីរដ្ឋា បានថ្លែងអះអាងថា:

" បើសិនជាគ្រប់គណបក្សប្រឆាំង និងគ្រប់ចលនានយោបាយទាំងអស់រួមគ្នាតែមួយនោះលោក ហ៊ុន សែន ពិតជាខ្ចាតចេញពីអំណាចដោយរាប់ចុះក្រោមពី១០០ថ្ងៃ (Count down) ជាក់ជាពុំខាន..." ។ មានន័យថាក្នុងរយៈពេល ១០០ ថ្ងៃលោក ហ៊ុន សែន ពិតជាអស់អំណាច ហើយគណបក្សប្រជាជនកម្ពុជាពិតជាដួលរលំ ។

គួរកត់សំគាល់ផងដែរថា បច្ចុប្បន្នក្រៅពីគណបក្សប្រឆាំងធំៗចំនួនពីរ ដូចជាគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ហើយនោះក៏នៅមានគណបក្សតូចៗជាច្រើនទៀតដែលសុទ្ធតែមាននិន្នាការប្រឆាំងនឹងការក្តោបក្តាប់អំណាចរបស់លោក ហ៊ុន សែន និងអះអាងពីភាពជាក់លាក់របស់ខ្លួនក្នុងការតំរង់នាវាកម្ពុជាឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យដ៏ត្រឹមត្រូវមួយ ។ ក្រៅពីនោះគេសង្កេតឃើញមានចលនាផ្សេងៗកំពុងតែផុសឡើងជាបណ្តើរៗ ដូចជាចលនាអំណាចពលរដ្ឋខ្មែរចលនាខ្មែរ ម្ចាស់ស្រុក ចលនាមហាចក្រខម ចលនាផ្កាឈូកសជាដើម ។ល។ ហួសនាពេលថ្មីៗនេះ ដែលមានចលនាកងទ័ពសេរីកម្ពុជា C.F.F (CAMBODIA FREEDOM FIGHTER) របស់លោក ឈុន យ៉ាសិទ្ធ ដែលមាននិន្នាការប្រឆាំងយ៉ាងផ្តាប់មុខទៅនឹងរាជរដ្ឋាភិបាលកម្ពុជា រហូតដល់ការផ្ទុះអាវុធមួយក្នុង "ប្រតិបត្តិការណ៍ភ្នំភ្លើង" កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០០នៅចំកណ្តាលទីក្រុងភ្នំពេញ ។ លោក ឈុន យ៉ាសិទ្ធ ត្រូវបានតុលាការសហរដ្ឋអាមេរិក កាត់ទោសកាលពីថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០១០ ឱ្យជាប់ពន្ធនាគារអស់មួយជីវិត ?ពីបទធ្វើរដ្ឋប្រហាររំលំរដ្ឋាភិបាលលោក ហ៊ុន សែន មិនបានសម្រេចកាលពីឆ្នាំ២០០០ ៕


**KHMER POST USA, LLC**
**East Coast Publication**

**Pin Samkhon,**
*Publisher & Editor-in-Chief*
Email: pinsamkhon@gmail.com
*Staff Writers:* **Loeum Im**

*Contributed Writers:*
**Mam Yin, Kim Phien**
*Advertising Department*

**Soben Pin**
KhmerPostUSA@gmail.com
**267-253-3947**

**Sam Khoeun**
*Sales Consultant*
**(781) 244-0522**

*Design Staffs:*
**Leang Heng & Mong Meng**

~~~~~~

KhmerPost USA, LLC is an independent newpaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local, community, and national news; and give an insight into Cambodia & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English.
It published twice a month in Pennsylvanian & Massachusett.

~~~~

Semimonthly edition subscription is available within the U.S. & Canada at $60.00 and 70 Euros in Europe per year.
Money order or check is accepted and made payable to:
KhmerPost USA, LLC
438 LINDLEY AVE.
Philadelphia, PA 19120

~~~

The Khmer Post has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge
effective date: 6/19/2009
~~~



# ទិវាស្វែងយល់អំពី សុខភាពសម្រាប់ ស្ត្រី អាស៊ី-អាមេរិកាំង ឆ្នាំទីប្រាំបី



## ថ្ងៃសៅរ៍ ទី២ ខែមិថុនា ឆ្នាំ២០១២

### ម៉ោង ៨ ព្រឹក ដល់ ១១:៣០ ព្រឹក

**Sheraton Philadelphia City Center Hotel**

**17th & Race Streets, Philadelphia**

មានអាហារពេលព្រឹក និងស្វាគមន៍ ដោយអ្នកទទួលភ្ញៀវពិសេស Elizabeth Hur, CBS3

*សិក្ខាសាលាស្តីអំពីសុខភាពស្ត្រី មានជាភាសាអង់គ្លេស និងភាសាអាស៊ីផ្សេងៗ ដោយឥតគិតថ្លៃ

*ខ្មែរ • ចិនកុកងឺ • ចិនកន្តាំង • គូចារ៉ាទី • ឥណ្ឌូណេស៊ី • កូរ៉េ • មេឡាយ៉ាឡាំ • ណេប៉ាល់ • វៀតណាម*

* សិក្ខាសាលាសម្រាប់អ្នកនៅរស់ពីរោគមហារីក និងអ្នកមើលថែរបស់ពួកគេ ដោយឥតគិតថ្លៃ

មានគ្រឿងកំសាន្តពីសហគមន៍អាស៊ី

មានព័ត៌មានផ្សេងៗអំពីសហគមន៍អាស៊ី

ចុះឈ្មោះថតសុដន់ការពាររោគមហារីក (mammograms) ដោយឥតគិតថ្លៃ

American Cancer Society®

THE OFFICIAL SPONSOR OF BIRTHDAYS.®

Susan G. Komen for the Cure® Philadelphia

cancer.org | 1.800.227.2345

komenphiladelphia.org | 215.238.8900

---

**លិខិតបំពេញដើម្បីចុះឈ្មោះ** សូមផ្ញើលិខិតចុះឈ្មោះនេះមកវិញឲ្យទាន់ ថ្ងៃសុក្រ ទី១៨ ខែឧសភា ឆ្នាំ២០១២

ឈ្មោះ៖ ______________________ លេខទូរស័ព្ទ៖ ______________

អាស័យដ្ឋាន៖ ______________________ ទីក្រុង៖ __________ រដ្ឋ៖ _____ លេខតំបន់៖ __________

** សូមរើសយកសិក្ខាសាលាតែមួយគត់៖*

❑ សិក្ខាសាលាសម្រាប់សុខភាពស្ត្រីទូទៅ

❑ សិក្ខាសាលាសម្រាប់អ្នកមានរោគមហារីកដែលនៅរស់ និងអ្នកមើលថែរបស់ពួកគេតែប៉ុណ្ណោះ (នឹងផ្តល់អ្នកបកប្រែភាសា។ សូមប្រាប់ភាសារបស់លោកអ្នក៖ ______________ )

សូមផ្ញើទៅ៖ Wan Ling Hung, American Cancer Society, 1626 Locust Street, Philadelphia, PA 19103

ឬ ទូរសារ៖ 215.985.5406

ឬ ទូរស័ព្ទ៖ 215.324.4070 ឬ 267.475.5073 Chanphy Heng, Cambodian Association of Greater Philadelphia (ខ្មែរ) ឬ

215.572.1234, Penn Asian Senior Services (APSSi) (ខ្មែរ) ឬ

215.985.5307, Wan Ling Hung, American Cancer Society (អង់គ្លេស)

សូមថ្លែងអំណរគុណជាពិសេសដល់៖

GlaxoSmithKline Oncology — CBS 3 HD — The CW Philly 57

*(Cambodian/Khmer)*

# "ស្ហិន យិន"ត្រឡប់មក សំដែងនៅហ្វីដែលហ្វៀ

# SHEN YUN RETURNS IN MAY!

## BRINGING TOGETHER 5,000 YEARS OF CHINESE CIVILIZATION

ល្ខោន បាឡេចិន នៅញូវយ៉កឈ្មោះ ស្ហិន យិន នឹងត្រឡប់មកសំដែង ល្ខោនបូរាណ ប្រវត្ត ៥ពាន់ឆ្នាំនៃវប្បធម៌ចិន នៅហ្វីឡាដែលហ្វៀ ជាថ្មីម្តងទៀត នៅថ្ងៃទី៨-៩ខែឧសភា ខាងមុខនៅរោងល្ខោន "មីរីយ៉ា"បន្ទាប់ពីបានសំដែងជូនទស្សនិកជនដ៏កុះករកាលពីថ្ងៃទី១៨ខែមីនា ឆ្នាំ ២០១២ មុន ។

ចាប់កំណើតតាំងពី៦០ឆ្នាំ បន្ទាប់ពីបដិវត្តន៍ចិនកុម្មុយនិស្តកាន់កាប់ប្រទេសចិន"ស្ហិន យិន" រួមប្រជុំដោយសិល្បៈកររបាំ នឹងភ្លេងដ៏ឆើតល្បី នឹងឈ្មោះ បានចេញសំដែងជុំវិញ ស.រ.អា នឹងពិភពលោកធ្វើឱ្យវប្បធម៌រាប់ពាន់ឆ្នាំនៃបូរាណចិនរស់រវើកឡើងវិញបាន ថ្វីត្បិតតែរបបកុម្មុយនិស្តប៉ុងប៉ងរំលាយកំចាត់ចោលក៏ដោយក្តី ។

សូមអានអត្ថាធិប្បាយជាភាសាអង់គ្លេសដូចតទៅ :



**Merriam Theater**
**May 8 - 9**

Philadelphia, PA (March 19, 2012) - After performing to sold-out audiences this season, including at New York City's Lincoln Center, Shen Yun Performing Arts will be returning to Philadelphia, just in time for Asian Pacific American Heritage Month.

Based in New York, Shen Yun Performing Arts was established in 2006 with the mission of reviving 5,000 years of divinely inspired Chinese culture. After more than 60 years of Communist rule in China, and especially after the Cultural Revolution, Chinese traditional culture has been all but completely demolished. Thus Chinese artists from fine arts performance backgrounds gathered together, inspired to bring their true culture back to life. The results of their collaboration are breathtaking in any language.

The greater Philadelphia region has contributed a number of artists from Shen Yun's three touring companies. Among this unprecedented gathering of world-class dancers, choreographers, vocalists and musicians are: Master of Ceremonies Leeshai Lemish, a graduate of Lower Merion High School, Dancer Jade Zhan from Newark, DE, Principal Lead Dancer Tim Wu from North Wales, PA, Conductor Ying Chen and Principal Flautist Ningfang Chen both from Sicklerville, NJ.


# GATEWAY FAMILY DENTAL

NOW OPENED AT GATEWAY CENTER II (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)



**DR. SERENA B. CHUOP**

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 10 years, she has been in private practices providing all aspects of General Dentistry. Dr. Chuop has opened a brand new state of the art dental practice that includes digital x-ray, paperless patient chart system, and brand new dental equipments.




**WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ**

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វ៉ែរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

www.gatewayfamilydental.com

**MOST DENTAL INSURANCES ACCEPTED**
**INCLUDING MASSHEALTH FOR KIDS**
**FINANCING AVALIABLE**
**យើងទទួលនូវគ្រប់ អ៊ិន ស្វ៊ិន**
**Masshealth for Kids**
**យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ**
**CALL FOR YOUR FREE CONSULTATION**
**(978) 455-5044**

# តមកទំព័រទី ១ តើគណបក្ស សម រង្ស៊ី នៅ...



យើងបានសម្រេចជាមួយគ្នាថា មកជួបជុំគ្នា នៅភោជនីយដ្ឋាន"ទេពធីតា" ដើម្បីអរគុណដល់ អ្នកស្រីអេលី ដែលធ្លាប់តែមានការជួយជ្រោម ជ្រែងដល់គណបក្ស ហើយនឹងអនុញ្ញាតិឱ្យលោក ប្រធានអាចអរគុណម្ចាស់ហាង ដោយផ្ទាល់ផង ។ ល្ងាចមិញយើងបានរៃអង្គាសបានប្រាក់មួយចំនួន ហើយព្រឹកនេះ យើងនឹងយកប្រាក់សល់ពីចំណាយ លើម្ហូបអាហារជូនលោក សម រង្ស៊ី ដើម្បីឱ្យលោក យកទៅកសាងជាតិជាបន្ថែមទៀត ។

**លោក សម រង្ស៊ី ប្រធានគណបក្សសមរង្ស៊ី**

ចំនួនភ្ញៀវដ៏ច្រើនដែលមកជួបជុំក្នុងពិធីយើង នាល្ងាចមិញនេះ ធ្វើឱ្យខ្ញុំរំភើប ហើយសូមកោត សរសើរដល់សមាជិកសមាជិការទាំងអស់ ដែល ខិតខំធ្វើការបំរើជាតិ ដែលធ្វើឱ្យខ្ញុំសប្បាយនឹង សម្តែងការដឹងគុណ នឹងគោរពដ៏ជ្រាលជ្រៅ ។

ខ្ញុំក៏សូមសម្តែងការដឹងគុណ នឹងអរគុណផង ដែរ ចំពោះសប្បុរសជនម្ចាស់ហាងទេពធីតា តំណាងដោយអ្នកស្រី អេលី ដែលតែងតែជួយជា ថវិកា នឹងជាសម្ភារៈដល់យើង ។ យើងជួបជុំគ្នា ពេលនេះ ដើម្បីរំលឹកការសប្បាយរីករាយ នឹងជោគ ជ័យរបស់យើង តែយើងត្រូវនិយាយផងដែរ អំពី អ្វីដែលយើងមិនពេញចិត្ត ឬក៏ធ្វើមិនបានសម្រេច ផងដែរ...។

**សុវណ្ណដារ៉ា នាង** : សុំឱ្យមានការទាក់ទង



រវាងគណៈកម្មការរដ្ឋផ្សេងៗជាមួយគ្នាឱ្យបានជិត ស្និទ្ធជាងមុន ជាពិសេសគណកម្មការរដ្ឋនីមួយៗ ត្រូវពង្រឹងការទាក់ទងគ្នា ដើម្បីបង្កើនចំនួន សមាជិក ចំនួននេះនឹងបង្កើនថវិកាសម្រាប់ទៅ ជួយដល់កម្ពុជា...។

**ឆាន់ ទូច** អគ្គលេខាធិការរង : ខ្ញុំសុំឱ្យគ្នា យើងផ្តល់លេខអ៊ីមែលដល់ខ្ញុំ ជាពិសេសចំពោះអ្នក ដែលចង់បានព័ត៌មានពីគ្នាយើងនៅតំបន់ឯទៀត



ពីព្រោះខ្ញុំជាអ្នកធ្វើកិច្ចការនេះ ជាមួយបង គិម លី កន្លងមកនេះដោយខ្ញុំមានការរវល់ជាពន់ពេក ធ្វើកិច្ចការទំនាក់ទំនងនេះ មិនបានជិតដល់ ខ្ញុំសូម អភ័យទោស តែខ្ញុំនឹងកែតម្រូវការងារនេះឱ្យបាន ប្រសើរឡើងវិញ ។

**មាស យន** :( គ្រូពេទ្យធ្មេញ ) ខ្ញុំចង់ឃើញ គណបក្សយើងខ្លាំង បើយោងតាមសេចក្តីប្រកាស របស់លោកប្រធាន ម្សិលមិញដែលខ្ញុំយល់ថា ជា ប្រវត្តិសាស្ត្រ គឺយើងត្រូវការកម្លាំងពីធនធានមនុស្ស



ឧទាហរណ៍ដូចជាមាននរណាម្នាក់ចង់ទៅឈរ ឈ្មោះនៅកម្ពុជា ត្រូវឱ្យមានការឆ្លងកាត់គណ កម្មការ អាមេរិកជាមុនសិន ដើម្បីឱ្យមានការគាំ ទ្រនូវជំហរនយោបាយ គុណសម្បត្តិមនុស្ស...។ ម្យ៉ាងទៀតអ្នកដែលត្រូវទៅធ្វើការក្នុងប្រទេស ត្រូវចូលប្រលូកពីទីនេះជាមុនសិន ដើម្បីឱ្យមាន បទពិសោធន៍ នឹងយល់ដឹងពីការងារក្នុងស្រុក...។

**សុខុម អ៊ុន** : សុំឱ្យតំណាងនៅតំបន់នីមួយៗ ឱ្យមានអណត្តិត្រឹមត្រូវ ពីព្រោះមនុស្សដែលនៅ កាន់អំណាចយូរអង្វែង ធ្វើឱ្យមានភាពទន់ខ្សោយ អសកម្ម...។



**ស៊ីនួន ខាំ** ខ្ញុំសុំឱ្យគណកម្មាធិការក្នុងរដ្ឋនីមួយៗ ត្រូវមានបញ្ជីការងារ ត្រូវមានគម្រោងសកម្មភាព ផ្ទាល់ដើម្បីធ្វើ ហើយត្រូវកំណត់ពេលសម្រាប់ធ្វើ ឱ្យបាន...ដូច្នេះអ្នកដែលមានតួនាទីត្រូវបំពេញការ



ងារឱ្យបានពេញលេញ ។

**ថាច់ ឈឿន** ខ្ញុំជាសមាជិកសកម្មផង ហើយមានតួនាទីមួយទៀត ដែលមិនមានសរសេរ នៅកន្លែងណាមួយ ដូចនេះសូមលោកប្រធាន ប្រាប់ឱ្យទាំងអស់គ្នាបានដឹងផង កុំឱ្យមានការ



សង្ស័យថា ហេតុអ្វីក៏ខ្ញុំចេះតែទាក់ទងពីគ្រោះ យោបល់លោកប្រធាន?

**ម៉ែន វណ្ណៈ** ខ្ញុំសុំឱ្យសមាជិកចាប់អារម្មណ៍ឱ្យ បានខ្លាំងលើតួនាទីមេឃុំ ដែលខ្ញុំពីដើមអតីតជា មេឃុំនៅកំពង់ធំ តួនាទីនេះ សំខាន់ណាស់ ដូចជា នៅពេលមេឃុំលុបឈ្មោះនរណាម្នាក់ទើប គ.ជ.ប



ហ៊ានដកឈ្មោះនោះចេញបាន...ដូច្នេះត្រូវនាំគ្នាជួយ ឱ្យបានឈ្នះនៅឃុំឱ្យបានច្រើន ពីព្រោះថា បើ យើង ចង់ឈ្នះនៅសភា គឺត្រូវឱ្យឈ្នះពីមូលដ្ឋាន ជាមុន ។

**សម រង្ស៊ី** នៅក្នុងការឱ្យយោបល់នេះ ខ្ញុំមាន ការចាប់អារម្មណ៍ចំពោះបញ្ហាទំនាក់ទំនងគ្នា ថា មានការខ្វះខាត អ្នកខ្លះពុំបានដឹងថា ខ្ញុំត្រូវមកទី នេះទេ...ដូច្នេះក្នុងឋានៈជាប្រធាន គឺខ្ញុំទទួលខុស មុនគេ ពីព្រោះខ្ញុំពុំបានជម្រុញអ្នកដឹកនាំ ស.រ.អា ឱ្យខិតខំទាក់ទងទៅតំបន់ឯទៀត អ៊ីចឹងទេ គ្នាក៏ ពុំមានព័ត៌មានគ្រប់គ្រាន់សម្រាប់ផ្សព្វផ្សាយបន្ត ពុំដឹងថា ត្រូវធ្វើអ្វីឱ្យបានច្បាស់លាស់នោះទេ ។ ខ្ញុំយល់ថា ដើម្បីឱ្យមានទំនាក់ទំនងជាប្រចាំយើង ត្រូវជួបប្រជុំតាមប្រព័ន្ធអាំងទែណែតតាមទូរស័ព្ទ ឱ្យបាន២ដងមុនពេលបោះឆ្នោត ដើម្បីរៀបចំកិច្ច ប្រជុំពីគ្រប់រដ្ឋឱ្យបានជារៀងរាល់ខែ គឺថ្ងៃ២២មេសា នេះម្តង ហើយថ្ងៃ២០ឧសភាម្តងទៀត អ្នករៀប ចំបច្ចេកទេស គឺលោក ឡារីសេង ។ ខ្ញុំសុំអញ្ជើញ ផ្ទាល់ ឱ្យប្រធានសាខារៀបចំការប្រជុំគ្នា១ខែម្តង ជាមួយសាខាឯ ទៀតៗនៅបរទេស នៅម៉ោង៤ ម៉ោង-ម៉ោងនៅញូវយ៉ក គឺ២ដងមុនពេលបោះ ឆ្នោត ហើយបន្តទៅក្រោយពេលបោះឆ្នោតទៀត ។

ទី២ ចំពោះអាណត្តិយើងសម្រេចឱ្យប្រធាន ធ្វើតែ២អាណត្តិទេ -រីឯករណីលោកជាគិមលី យើងដឹងថា លោកបានចប់អាណត្តិពីខែ១១ឆ្នាំ ២០១១ យើងបានសម្រេចឱ្យបន្តដល់ខែ១១ឆ្នាំ ២០១២ ដើម្បីឱ្យយើងអាចផ្តោតអារម្មណ៍ទៅ លើការបោះឆ្នោតនៅស្រុកខ្មែរជាមុន ។

**ទី៣**-ខ្ញុំឯកភាពចំពោះអ្នកទៅឈរឈ្មោះនៅ ស្រុកខ្មែរ សុំឱ្យឆ្លងកាត់គណបក្សកម្មាធិការ ស.រ អា ជាមុន បើមានឈ្មោះណាច្បាស់លាស់ដែល ចង់លើកប្រាប់ខ្ញុំ អាចទូរស័ព្ទមកខ្ញុំពេលក្រោយ ក៏បានដែរ ។

ទី៤-លោក ឆាន ទូច ជាអគ្គលេខាធិការរង សុំឱ្យទទួលស្គាល់ថា ជាតួនាទីសំខាន់របស់គណ កម្មាធិការយើង លោកធ្លាប់ជាប្រធានសាខាបក្ស ផង ។

ទី៥-ចំពោះការអនុវត្តន៍ការងារឱ្យបានច្បាស់ លាស់ខ្ញុំក៏សុំឯកភាពដែរ គឺតែកាន់តំណែងណា មួយត្រូវបំពេញតួនាទីឱ្យសកម្ម សូមឱ្យមានការ ដាសតឿនផង ។

ទី៦-អរគុណលោក រដ្ឋា ខៃ ដែលមានគំនិត ធ្វើ Fundraising ឱ្យគណបក្ស ខ្ញុំជឿថា អស់ លោកទីនេះ មានសមត្ថភាពខ្ពស់ណាស់ ក្នុងរឿង នេះ ។

ទី៧-តំណែងតួនាទីលោក ថាច់ ឈឿន គឺ លោកជាទីប្រឹក្សាផ្ទាល់ដែលដោយសារភាពចាស់ ទុំនឹងបទពិសោធន៍របស់គាត់ ខ្ញុំតែងតែសួរយោ បល់គាត់ជាញឹកញយ តែមិនមែនបានន័យថា ខ្ញុំ បិទទ្វារមិនស្តាប់អ្នកដទៃទៀតនោះទេ-នរណា ក៏ខ្ញុំពេញចិត្តនឹងទទួលយោបល់ដែរ-តែទាំងអស់ គ្នា ក៏ត្រូវតែគោរពវិន័យនឹងក្រឹត្យក្រមរបស់ គណបក្សមិនឱ្យខ្វះខាតទេ ទោះជាទីប្រឹក្សាផ្ទាល់ ក៏ដោយ...៕





華 China Star 星
ភោជនីយដ្ឋាន ឆាយណាស្តារ
មានម្ហូបចិន
ម្ហូបប៉ូលីណេស៊ី
ម្ហូបចិនកប់តុង
ម្ហូបម៉ង់ដារិន
Chinese -Polynesian -Cantonese -Mandarin
369 Broadway St., Lowell, MA 01854
Tel: 978-454-7578, 978-454-7507
Open Daily: Sun. to Thurs. 11:00 AM to 1:00 AM
Fri. and Sat. 11:00 AM to 3:00 AM
យើងអាចយកម្ហូបទៅដល់ផ្ទះបាន
We Deliver All Day: 11:30 AM to 1:00 AM Available to most areas. Min. $10.00 Delivery Charge $2
$19.95
បង្កងឆាខ្ទឹម និងខ្ញីពិសេស
SPECIAL 2 Lobsters w/ Scallion & Ginger




SIM'S
Major Sim Enterprises, Inc.
Home Improvement
ជាងសំណង់តាស៊ីម
License#CS 88569 Registration#153685
978-452-7467 / 978-421-3672 / 978-420-8551
FREE ESTIMATES
60 Middlesex St. (Rte.110) Lowell. MA 01852
FULLY INSURED
ជួសជុល កែលំអរ សង់បន្ថែម
• Kitchen ចង្ក្រានបាយ
• Livingroom បន្ទប់ទទួលភ្ញៀវ
• Bathroom បន្ទប់ទឹក
• Bedroom បន្ទប់ដេក
• Roofing ដំបូល
• Siding ជញ្ជាំង
• Window បង្អួច
• Door ទ្វារ
• Basement ជាន់នៅក្រោមដី
• Additions បន្ទប់បន្ថែម
Residential • Commercial • Industrial
ទទួលប្រាក់គ្រប់ប្រភេទ
Bank Loan, Insurance, Compensation, Credit Debit Card, Check &Cash
More information call: 1.978.452.7467
www.simshomeimprovement.com
Boreth@simshomeimprovement.com




NEW
CHINA PEARL
DIM SUM •RESTAURANT •BAR
ឌីមសាម ភោជនីយដ្ឋាន និងបា
ភោជនីយដ្ឋាន "ញូឆាយណាភើល" សូមអញ្ជើញលោកអ្នកនិងក្រុមគ្រួសារមករីករាយជាមួយម្ហូបអាហារមកពីហុងកុង និងប្រទេសអាស៊ីនានាជុំវិញ ។ យើងមានសាលរាំកំសាន្តសំរាប់ពិធីការ ឬរាត្រីជួបជុំគ្នា មានបានិងខារ៉ាអូខេ ទៀតផង ។ កន្លែងចតឡានមិនយកថ្លៃ ហើយមានសុវត្ថិភាពល្អ ។
មានឆាករាំសំរាប់ពិធីការ ឬប្រជុំកំសាន្ត
មានឌិនស៊ុមរាល់ថ្ងៃ
មានម្ហូបគ្រឿងសមុទ្រស្រស់រាល់ថ្ងៃ
សៀវភៅមុខម្ហូបយើងខ្ញុំមានរាប់រយមុខ ដូច China town
ដែលលោកអ្នកការកុម្មង់បានតាមតម្រូវការ
BUSINESS HOURS: Mon - Wed 11 a.m. - 10 a.m./Thurs. & Fri. 11 a.m. - 12 Midnight / Sat. 10 a.m. - 12 Midnight
Sun.10 a.m. – 10 p.m. Delivery Hours 11 a.m. – 9 p.m. min. $15 order plus $2 delivery.
288 Mishawum Rd., Woburn, MA 01801 / Phone:(781) 932-0031/ www.NewChinaPearl.com
From Boston 95 South; Exit 37B, from Lowell / 93 South; Exist 37B, from RT-128; Exit 36.

## សិក្ខាសាលាស្តីពីការទិញផ្ទះលើកទី១
## First Time Home Buyer Workshops



សូមអញ្ជើញចូលរួមជាមួយយើង ដើម្បីរៀបចំខ្លួនទិញផ្ទះទី១របស់លោកអ្នកឲ្យបានពីរដង់ក្នុង១ខែ នាឆ្នាំ២០១២ នេះ យើងនឹងបង្រៀនលោកអ្នកមួយជំហ៊ានម្តងៗរៀបចំឲ្យចេញពីBad Credit ឬគ្មាន Credit ទៅរកថវិការ ទៅសំណើរសុំខ្ចីប្រាក់ទិញផ្ទះនឹងទៅរកសោនៃផ្ទះរបស់លោកអ្នកបានសេវាយើងនេះមិនមានយកកំរៃនិយាយ ភាសាខ្មែរ ហើយគ្មានចេញថ្លៃអ្វីទាំងអស់ បើលោកអ្នកមានបញ្ហាត្រូវគេរឹបអូសយកផ្ទះយើងក៏អាចជួយបានដែរ –សូមអញ្ជើញទូរស័ព្ទរកដេវីដ អូ សេង ថ្ងៃនេះ បើចង់ដឹងព័ត៏មានពីការទិញផ្ទះនេះ បន្ថែម ឬក៏ចង់ដឹងថា តើ យូណាយតិក អាចជួយលោកអ្នកបានប៉ុណ្ណា? គឺទូរស័ព្ទ 215-467-8700 x219

សូមអញ្ជើញចុះឈ្មោះថ្ងៃនេះ ដើម្បីចូលសិក្ខាសាលាតាមថ្ងៃខែដូចតទៅ:

ថ្ងៃអង្គារ៍ ៣១ មករា ២០១២ពីម៉ោង ៥:៣០ដល់៩:៣០ ល្ងាច

ថ្ងៃព្រហស្បត្តិ៍ ១៦ កុម្ភ: ២០១២ ពីម៉ោង ៥:៣០ ដល់៩:៣០ល្ងាច

ថ្ងៃអង្គារ៍ ២៨ កុម្ភ: ២០១២ ពីម៉ោង ៥:៣០ ដល់ ៩:៣០ ល្ងាច

ថ្ងៃព្រហស្បត្តិ៍ ១៥ មិនា ២០១២ ពីម៉ោង ៥:៣០ដល់៩:៣០ល្ងាច

ថ្ងៃអង្គារ៍ ២៧មិនា ២០១២ ពីម៉ោង ៥:៣០ ដល់៩:៣០ល្ងាច

ព័ត៌មានបន្ថែមស្តីពីសិក្ខាសាលាសូមអញ្ជើញទូរស័ព្ទទៅ 215-467-8700

United Communities of Southeast Philadelphia

2029 s. 8 TH Street.
(8th & Snyder Ave)
Philadelphia, PA 19148

Tel. 215 -467-8700 ext. 220
Fax: 215 -467-1042
www.ucsep.org

United Communities
Southeast Philadelphia



## ហាងមាសរស្មី
## SUNSHINE JEWELRY, INC.
**215-271-2950**



**Certified Diamonds & Golds (24K & 18K)**
**Men & Women Jewelries & Watches**
**Custom Design & Repairs on Premise**
**15 Years in Services & Growing Strong**





702 Washington Ave. Phila., PA 19147
www.sunshinejewelryonline.com



## ឱសថស្ថាន TRX PHARMACY

**5520 Whitaker Avenue Unit C (Next To BEN CITY)**
**PHILADELPHIA, PA 19124 TELEPHONE: 215-288-8701**



### ម្ចាស់ហាង: ស៊ីវ អេង

- យើងទទួលយកអ៊ិនស្វ៊ិនស្ទើរតែទាំងអស់
- អាចយកថ្នាំទៅជូនដល់ផ្ទះ
- មានគម្រោងបង់ថ្លៃពិសេស សម្រាប់ "ខូប៉េយ" ដែលមានតម្លៃខ្ពស់
- ពិសេស: មានជូនកំរៃ៤៥សម្រាប់អ្នកមកទិញថ្មីដែលមានការផ្ទេរវេជ្ជបញ្ជា
- កន្លែងចតឡានធំទូលាយ
- សេវាត្រឹមត្រូវច្បាស់លាស់ មានវិជ្ជាជីវៈធ្វើការលឿន
- មានរង្វាន់ បើយកវេជ្ជបញ្ជាមកទិញថ្នាំ

**ពិសេស**: ជូនម្សៅអិនស្វមួយកំប៉ុងពេលទិញតាមវេជ្ជបញ្ជា១០មុខ មានសំរាប់ភ្ញៀវដែលគ្មាន អិនស្វ៊ិន មានថ្នាំជេណេរិត ច្រើនរាយមុខតម្លៃ $14.99 សំរាប់៩០ថ្ងៃ ថ្នាំអនតាយបាយូទិក ដូចជា Amoxicillin, Ampicillin, Cephalesin តម្លៃ $4



**រាល់ខែមានចាប់ឆ្នោតសម្រាប់អ្នកយកថ្នាំនៅទីនេះ អាចត្រូវឆ្នោតវត្ថុ ដូចជា Telephone Samsung Galaxy ឬ Ipod Touch**





**គាំទ្រគ្រូពេទ្យប្រចាំគ្រួសារមាន:**

TRUONG NGUYEN, MD
5746 Rising Sun Avenue
Philadelphia, PA 19120
**215-904-6891**

KENNETH NGUYEN, MD
448 E WYOMING AVE
Philadelphia, PA 19120
**215-324-2180**

NICHOLAS TRUONG, MD
133 EAST LEHIGH AVE
Philadelphia, PA 19125
**215-426-9344**

# បោសសំអាតទីតាំងផលិតគ្រឿងញៀនទ្រង់ទ្រាយធំមេក្លោងជិះរថយន្តម៉ែកស៊ីដេសគេចខ្លួនដោយសុវត្ថិភាព

ដោយ : សេងឡុង

យ៉ាងហោចណាស់ជនល្មើសចំនួន១១នាក់ ក្នុងនោះជនជាតិវៀតណាម ចំនួន៦នាក់និងខ្មែរចំនួន៥នាក់ត្រូវបានចាប់ឃុំខ្លួនក្នុងប្រតិបត្តិការចុះបង្ក្រាប និងបោសសំអាតកន្លែងផលិតគ្រឿងញៀនមិនទាន់បានសម្រេចជាច្រើនទីតាំង ស្ថិតនៅ ខណ្ឌសែនសុខ ខណ្ឌពោធិ៍សែនជ័យនិងខណ្ឌមានជ័យអស់រយៈពេលពេញមួយយប់ថ្ងៃទី០១ ខែឧសភា និងពេញមួយថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១២ ដោយមានការចូលរួមពីសំណាក់កម្លាំងចម្រុះជាច្រើនស្ថាប័ន ប៉ុន្តែមេក្លោងធំនៃបណ្តាញចាត់តាំងការផលិតនិងជួញដូរគ្រឿងញៀនដ៏ធំមួយនេះកំពុងដើរហើរយ៉ាងមានសេរីភាពនៅឡើយ ។







លោក ទូចណារ៉ុថ ស្នងការនគរបាលរាជធានីភ្នំពេញបានឱ្យដឹងថាចាប់តាំងពីក្បាលព្រលប់រហូតដល់ទៀប ភ្លឺ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១២សមត្ថកិច្ច បានចុះឆែកឆេរ ឃ្លាំងចំនួន២ នៅតាម បណ្តោយផ្លូវលេខ២០០៤ ក្នុងសង្កាត់ទឹកថ្លា ខណ្ឌសែនសុខដែលគេដឹងថាជាកម្មសិទ្ធិរបស់ឧកញ្ញាម្នាក់ដែលជួលឱ្យអ្នកដទៃ រួចបន្តទៅឆែកឆេរផ្ទះ កន្លែងទៀត ដាក់យីហោក្រុមហ៊ុនខេអេចអ៊ិន ធីហ្គោល ដែលស្ថិតនៅតាមបណ្តោយផ្លូវ លេខ៣១០ក្នុងសង្កាត់បឹងកេងកងទី២ ខណ្ឌ ចំការមនតាមរយៈការបង្ហាញរបស់ជនល្មើស ជាជនជាតិវៀតណាមពីរនាក់ ។ បន្ទាប់ពីចុះឆែកឆេរនិងឃាត់ខ្លួនជនពាក់ព័ន្ធបន្ថែមចំនួន៥នាក់ ក្នុងនោះមានស្រី៣នាក់សមត្ថកិច្ចបានបន្តចុះទៅឆែកឆេរនៅផ្ទះល្វែងមួយកន្លែងទៀត ស្ថិតនៅខាងជើងផ្សារសុវណ្ណា ក្នុងសង្កាត់ទំនប់ទឹកខណ្ឌចំការមន រួចហើយបន្តទៅឆែកឆេរនៅទីតាំងផលិតដ៏ធំក្នុងផ្ទះល្វែងមួយកន្លែង ស្ថិតនៅឈាងខាងមុខស្ថានីយ៍ទូរទស្សន៍អាស៊ីអាគ្នេយ៍ ក្នុងសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ។

សមត្ថកិច្ចបានបញ្ជាក់ទៀតថាក្រោយបញ្ចប់ការចុះឆែកឆេរទីតាំងខាងលើនេះ កម្លាំងចម្រុះបានបន្តទៅឆែកឆេរផ្ទះល្វែងមួយកន្លែងទៀតដែលមេក្លោង ជួញដូរគ្រឿងញៀនជួលឱ្យស្រីស្នេហ៍របស់ខ្លួនរស់នៅស្ថិតនៅទល់មុខស្ថានីយ៍វិទ្យុជាតិ ក្នុងភូមិឫស្សីសង្កាត់ស្ទឹងមានជ័យខណ្ឌមានជ័យ ។ មានការបង្ហើបឱ្យដឹងថាមេក្លោងជួញដូរគ្រឿងញៀន មានឈ្មោះឡុង ហើយជនល្មើសចំនួន១១នាក់ ដែលត្រូវបានឃាត់ខ្លួននោះ គឺជាមនុស្សយ៉ាងជំនិតរបស់មេក្លោង ដែលកំពុងរត់គេចខ្លួនទំនងជាចាកចេញពីប្រទេសកម្ពុជាឬនៅទីកន្លែងដ៏សុវត្ថិភាពណាមួយ ។

ប្រតិបត្តិការចុះបោសសំអាតគ្រឿងញៀននេះត្រូវបានធ្វើឡើង បន្ទាប់ពីមានការស្រាវជ្រាវយ៉ាងសម្ងាត់អស់រយៈពេលជាច្រើនខែមកហើយ លោកទូច ណារ៉ុថ បានឱ្យដឹងថានេះគឺជាប្រតិបត្តិការដ៏ធំមួយ ដែលមិនធ្លាប់មានពីមុនមកដោយសមត្ថកិច្ចរកឃើញប្រេងម្រះព្រៅចំនួន ១២៧ប៊ីដុងក្នុងមួយប៊ីដុង មានចំណុះ ២៥ លីត្រ ហើយក្នុងនោះមានអាល់កុលនិងថ្នាំញៀនខ្លះផងដែរគឺ ការបង្ក្រាបនេះបានធ្វើឡើងទាន់ពេលវេលា ក្នុងការទប់ស្កាត់

តទៅទំព័រទី ១៦






# The KP Press Club

## Presents the 2nd Annual Media & Community Building Gathering

Sponsored by

Neighborhood Health Plan of Rhode Island

KhmerPost USA
Printing the Camodian world News

SWH
SENIOR WHOLE HEALTH



## សេចក្តីអញ្ជើញ


Roger Samkhon Pin, Publisher & Editor-in-Chief

***ដល់បងប្អូនខ្មែរ មានថ្នាក់ដឹកនាំ អ្នកប្រកបរបរពាណិជ្ជកម្ម ឬអ្នកផ្តល់សេវាកម្មនានា ដែលរស់នៅម៉ាសាឈូសេត រ៉ូដអាយឡិន ញូហាមស្ពឺ និងកុណិចទីកិត***

សូមអញ្ជើញមកចូលរួមក្នុងកម្មវិធី "ប្រេសក្លឹបពិសេស" សំរាប់បងប្អូន ក្នុងតំបន់បញ្ចេញសម្លេងបង្កើតទំនាក់ទំនងតាម "ណេតវើក" ដ៏សំខាន់ ដែលខ្មែរប៉ុស្តិ៍ ស.រ.អា ខិតខំកសាងជូនសហគមន៍ខ្មែរ តាំងពីជាង៥ឆ្នាំមកហើយ ។

អាចនឹងជួយបង្កើនទំនាក់ទំនងពាណិជ្ជកម្ម ឬជួបអ្នកនយោបាយក្តី ក្នុងឱកាសកាសល្បៀងសាយភោជដ៏ឈ្ងុយឆ្ងាញ់នៅភោជនីយដ្ឋានដ៏ធំល្អមួយរបស់ជនជាតិអាស៊ីលោកអ្នកនឹងចូលរួមសកម្មភាពពិតមានរបៀបថ្មីមួយ ដែលជនជាតិអាស៊ីយើងពុំដែលបានធ្វើពីមុនមកនៅក្នុងតំបន់នៅ ឡើយទេ ។

សូមលោកអ្នកអញ្ជើញចូលរួមក្នុងឱកាសដ៏កម្រនៃ "ប្រេសក្លឹបនេះ" បើកជូនលោកអ្នកជាពិសេស សំរាប់តំបន់កុំបីអាក់ខានឡើយ ។

យើងបានជ្រើសយកភោជនីយដ្ឋានដ៏ធំបង្អស់មួយនៅផ្លូវជាតិខ្វែង៩៣ និង៩៥ ហើយទទួលលោកអ្នកជាមួយម្ហូបប្រណីត៨មុខ ចំអិនដោយចុង ភៅជាតិចិនដ៏ឆ្នើម ដើម្បីបណ្តែតអារម្មណ៍ជាមួយគ្នាក្នុងបរិយាកាសនៃអធិរាជក្រុងចិនបូរាណផង ។ **សូមអរគុណ ពិន សំខុន**

Date: **Friday, May 4th, 2012**
Time: **5:30 – 9:30 p.m.**
Place: **New China Pearl Restaurant, 288 Mishawum Road. Woburn, MA.**
